**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានសន្តប៉ូល**

Saint Paul Institute

# ការណែនាំជាមូលដ្ឋានសម្រាប់ ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

(Distance and E-Learning)

ដើម្បីឱ្យការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning) ប្រកបដោយក្រមសីលធម៌ មានដំណើរការទៅដោយជោគជ័យ និងប្រសិទ្ធភាព វិទ្យាស្ថានសន្តប៉ូល តម្រូវឱ្យសាស្ត្រាចារ្យទាំងអស់គោរពឱ្យបានខ្ជាប់ខ្ជួននូវការណែនាំដូចខាងក្រោម៖

## ១. សម្រាប់សាស្ត្រាចារ្យ

១.១. សាស្ត្រាចារ្យត្រូវបង្រៀនមេរៀនឱ្យស្របតាមកម្មវិធីសិក្សា ដែលវិទ្យាស្ថានបានកំណត់។

១.២. សាស្ត្រាចារ្យមាន**តួនាទីយ៉ាងសំខាន់ក្នុងការបង្រៀន និងសម្របសម្រួល**ម៉ោងសិក្សាដែលសាស្ត្រាចារ្យបង្រៀន។

១.៣. មិនត្រូវ **ថត ឬ កាត់**យកផ្នែកណាមួយនៃវីដេអូបង្រៀន ឯកសារបង្រៀន និងពាក្យសំដីនៅក្នុងថ្នាក់រៀនជាមួយនិស្សិតនៅវិទ្យាស្ថានសន្តប៉ូលទៅ**ចែករំលែក**បន្តនូវក្នុងបណ្តាញសង្គម ឬ អ្នកដែលគ្មានការពាក់ព័ន្ធ។

១.៤. សាស្ត្រាចារ្យទាំងអស់ត្រូវប្រើប្រាស់សំណួរ ចម្លើយ យោបល់ ឬ ការសន្ទនាដែលទាក់ទងនឹងមេរៀនប៉ុណ្ណោះ ហើយត្រូវប្រកាន់ភ្ជាប់នូវ**ក្រមសីលធម៌**។

១.៥. សាស្ត្រាចារ្យទាំងអស់ត្រូវ**ជៀសវាងការប្រើប្រាស់ពាក្យដែលមានអត្ថន័យប្រមាថ ឬ ប៉ះពាល់ ចំពោះគ្នាទៅវិញទៅមក ចំពោះបុគ្គលផ្សេងៗ ចំពោះរាជរដ្ឋាភិបាល ជាពិសេសចំពោះព្រះចេស្តាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**។

១.៦. សាស្ត្រាចារ្យទាំងអស់មិនអនុញ្ញាតឱ្យពិភាក្សា ឬ **ធ្វើការសន្ទនាដែលទាក់ទងនឹងនយោបាយ**ដាច់ខាតនៅក្នុងថ្នាក់រៀន ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning)។

១.៧. **ការលេងសើច ការសន្ទនាប្រកបដោយកំហឹង និងភាពអវិជ្ជមាន** ដែលធ្វើឱ្យប៉ះពាល់/រំខានដល់ការសិក្សាត្រូវបានហាមឃាត់។

១.៨. សាស្ត្រាចារ្យ**ត្រូវបង្កើតបរិយាកាសរៀនសូត្រ ដែលសប្បាយរីករាយ ដែលមិនដាក់សំពាធ ត្រូវផ្តល់ឱកាស និងជំរុញលើកទឹកចិត្តនិស្សិតទាំងអស់ចូលរួមចែករំលែក ផ្លាស់ប្តូរគំនិត ពង្រីកការគិតរបស់ពួកគេឱ្យកាន់តែស៊ីជម្រៅ បង្កើនបញ្ញា តាមរយៈ ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning)**។

១.៩. ក្រោយនិស្សិតផ្ញើកិច្ចការដែលបានធ្វើរួច មកកាន់សាស្ត្រាចារ្យ សាស្ត្រាចារ្យត្រូវ**ដាក់ពិន្ទុ**គ្រប់កិច្ចការដែលនិស្សិតបានធ្វើដោយ**តម្លាភាព** និងបញ្ជូនទៅកាន់ការិយាល័យសិក្សាតាមការកំណត់។

១.១០. **ហាមដាច់ខាតក្នុងការបង្កើតមេរៀនបង្រៀន វីដេអូ លំហាត់ ឯកសារបង្រៀនផ្សេងៗ ដែលប្រើប្រាស់សម្រាប់បង្រៀននៅវិទ្យាស្ថានសន្តប៉ូល ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning) ដោយគ្មានប្រភពច្បាស់លាស់ និងឯកសារយោងត្រឹមត្រូវ**។

១.១១. សាស្ត្រាចារ្យដែលមិនបានគោរពទៅតាមលក្ខខណ្ឌនេះ នឹងត្រូវទទួល**ពិន័យ**ទៅតាម**វិន័យ**របស់វិទ្យាស្ថាន ឬទទួលខុសត្រូវតាមច្បាប់ដោយបុគ្គលផ្ទាល់។

ថ្ងៃច័ន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៣

ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

**នាយកវិទ្យាស្ថាន**

**ផុន_សុផល**

**វិទ្យាស្ថានសន្តប៉ូល . ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ** ភូមិអង្គគគី ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ (ខាងជើងផ្សារអង្គតាសោម)
SAINT PAUL INSTITUTE - THE APOSTOLIC VICARIATE OF PHNOM PENH ANGKORKI VILLAGE, TAPAM COMMUNE, TRAMKOK DISTRICT, TAKEO PROVINCE, CAMBODIA
**Phone: (855-32) 63 90 003 E-mail: spi.takeo@gmail.com Website: www.spi.edu.kh Facebook: Saint Paul Institute**